Disability Rights California

**Pub#F127.06 Cambodian – March, 2020**

**សិទ្ធិរបស់អ្នកដែលមាន IDD**

## វីរុស Coronavirus (COVID-19) សិទ្ធិរបស់ពលរដ្ឋមានពិការភាពផ្នែកសតិបញ្ញា និងការវិកលូតលាស់ ដែលរស់នៅតែឯង ឬ ជាមួយក្រុមគ្រួសារ

**ទំព័រនេះនឹងត្រូវធ្វើបច្ចុប្បន្នភាពនៅពេលមានព័ត៌មានបន្ថែម*

ត្រូវបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃ 23 មីនា 2020

ព័ត៌មាននេះសម្រាប់ពលរដ្ឋមានពិការភាពផ្នែកសតិបញ្ញានិងការវិកលូតលាស់ ដែលរស់នៅដោយខ្លួនឯង ឬ ជាមួយក្រុមគ្រួសារ ហើយទទួលបានសេវាកម្មពី "មជ្ឈមណ្ឌលក្នុងតំបន់"។

## តើមជ្ឈមណ្ឌលក្នុងតំបន់ជាអ្វី?

មជ្ឈមណ្ឌលក្នុងតំបន់គឺជាចំណុចសំខាន់នៃទំនាក់ទំនងរបស់អ្នក ដើម្បីទទួលបានសេវាកម្ម និងការគាំពារនានា។ អ្នកអាចស្វែងរកព័ត៌មានទំនាក់ទំនងសម្រាប់មជ្ឈមណ្ឌលក្នុងតំបន់តាមដំណភ្ជាប់នេះ៖ https://www.dds.ca.gov/rc/listings/

## តើមជ្ឈមណ្ឌលក្នុងតំបន់អាចជួយអ្នកត្រៀមខ្លួនសម្រាប់វីរុស COVID-19 បានយ៉ាងដូចម្តេច?

បច្ចុប្បន្ននេះ ជាពេលល្អដើម្បីធ្វើផែនការសម្រាប់គ្រាអាសន្នដូចជាវីរុស COVID-19។ សូមទាក់ទងទៅកាន់អ្នកសម្របសម្រួលសេវាកម្មមជ្ឈមណ្ឌលក្នុងតំបន់របស់អ្នក។ សូមស្នើសុំពួកគេឲ្យជួយអ្នកបង្កើតផែនការក្នុងករណីដែលអ្នកថែទាំរបស់អ្នកលែងអាចជួយអ្នកបាន ដោយសារតែវីរុស COVID-19។ អ្នកអាចសួរនាំពីអ្វីដែលនឹងកើតឡើង ប្រសិនបើអ្នកនឹងចូលរួមកម្មវិធីមួយក្នុងពេលថ្ងៃ ដែលប្រាប់អ្នកថាវាត្រូវតែបិទនោះ។

## IHSS និង អ្នកមើលថែទាំផ្សេងទៀត៖ តើអ្វីទៅជាផែនការរបស់ខ្ញុំ និង អ្វីដែលថ្នាក់មូលដ្ឋានអាចធ្វើបាន?

ប្រសិនបើពឹងផ្អែកទៅលើ IHSS ឬ អ្នកមើលថែទាំផ្សេងទៀត ពីកម្មវិធីទាំងឡាយដែលមិនត្រូវបង់ប្រាក់ដោយមជ្ឈមណ្ឌលក្នុងមូលដ្ឋានទេនោះ សូមសាកសួរអ្នកមើលថែទាំរបស់អ្នក ដើម្បីជួយធ្វើផែនការអ្នក ប្រសិនបើពួកគេជួយអ្នកលែងបានទៀតហើយនោះ។

អ្នកក៏អាចស្នើសុំដល់អ្នកសម្របសម្រួលមជ្ឈមណ្ឌលក្នុងមូលដ្ឋានរបស់អ្នកបានផងដែរ ដើម្បីឲ្យជួយធ្វើផែនការរបស់អ្នកបានផងដែរ។ នេះគឺដោយសារតែមជ្ឈមណ្ឌលក្នុងតំបន់អាចបង់ថ្លៃសេវាផ្សេងៗគ្នា ក្នុងករណីដែលអ្នកមើលថែទាំ IHSS របស់អ្នកលែងទំនេរទៀតហើយនោះ។ សេវាកម្មទាំងនេះរួមមានៈ

- សេវាថែទាំប្រចាំថ្ងៃ ឬ សេវាមេផ្ទះ៖ សេវាទាំងនេះគឺដូចគ្នាច្រើនទៅនឹង IHSS អញ្ចឹងដែរ។ សេវាទាំងនោះត្រូវបានបង់ប្រាក់ដោយមជ្ឈមណ្ឌលក្នុងតំបន់ មិនមែនដោយខោនធីទេ។
- ការសម្រាកៈ សេវានេះជួយដល់អ្នកមើលថែទាំរបស់អ្នក ឲ្យជួយដល់អ្នកដោយធានាថាពួកគេអាចសម្រាកបាន។
- បំណិនការរស់នៅដោយឯករាជ្យ ឬ សេវាគាំទ្រការរស់នៅ៖ សេវាទាំងនេះជួយដល់ពលរដ្ឋឲ្យរស់នៅបានដោយឯករាជ្យតាមតែអាចធ្វើទៅបាននៅក្នុងផ្ទះផ្ទាល់ខ្លួនរបស់គេ ជាមួយនឹងការគាំពារដែលគេត្រូវការ។

សូមសាកសួរមជ្ឈមណ្ឌលក្នុងតំបន់របស់អ្នកអំពីជម្រើសទាំងនេះ និងជម្រើសផ្សេងទៀត ដែលអាចមាន។ មួយចំនួននៃសេវាទាំងនេះ អាចត្រូវផ្តល់ដោយសមាជិកគ្រួសារ ឬ អ្នកដែលបានស្នាក់នៅជាមួយអ្នក។

## តើអ្វីទៅជាតួនាទីរបស់ក្រសួងសេវាការលូតលាស់?

ក្រសួងសេវាការលូតលាស់ ជាទីភ្នាក់រដ្ឋទទួលបន្ទុកមជ្ឈមណ្ឌលក្នុងតំបន់ទាំងអស់ចំនួន 21។ ទីភ្នាក់ងារនេះពេលខ្លះត្រូវបានគេហៅថា DDS។

DDS មានអំណាចប្រាប់ដល់មជ្ឈមណ្ឌលក្នុងតំបន់ពីអ្វីដែលត្រូវធ្វើ។ ដោយសារតែវីរុស COVID-19 DDS បានប្រាប់ទៅដល់មជ្ឈមណ្ឌលក្នុងតំបន់ឲ្យធានាថា ពលរដ្ឋដែលទទួលសេវាពីមជ្ឈមណ្ឌលក្នុងតំបន់ មានសុខភាពល្អ និងសុវត្ថិភាព។ ឧទាហរណ៍៖

- DDS បានប្រាប់ដល់មជ្ឈមណ្ឌលក្នុងតំបន់ថាមិនអីទេ បើមិនជួបនឹងពលរដ្ឋដោយផ្ទាល់នោះ។ ជំនួសមកវិញ មជ្ឈមណ្ឌលក្នុងតំបន់អាចប្រើបច្ចេកវិទ្យាដូចជាតាមទូរសព្ទ សន្និសិទ្ធតាមវីដេអូ Skype និង Face Time បាន។ អ្នកអាចជជែកជាមួយនឹងមជ្ឈមណ្ឌលក្នុងតំបន់របស់អ្នកអំពីជម្រើសទាំងនេះ និងរបៀបដំណើរការជម្រើសទាំងនេះ។
- DDS បានផ្តល់មជ្ឈមណ្ឌលក្នុងតំបន់នូវអំណាច ដើម្បីបង់ថ្លៃដល់អ្នកផ្តល់សេវានូវទឹកប្រាក់កាន់តែច្រើនជាងមុន ដើម្បីរក្សាពលរដ្ឋឲ្យមានសុខភាពល្អ និងសុវត្ថិភាពដោយសារតែវីរុស COVID-19។ នេះត្រូវបានគេហៅថា

“ការលើកលែងផ្នែកសុខភាពនិងសុវត្ថិភាព (Health and Safety Waiver Exemption)”។ សូមសាកសួរមជ្ឈមណ្ឌលក្នុងតំបន់របស់អ្នក ក្រែងនេះអាចជម្រើសសម្រាប់អ្នក។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមអំពីសិទ្ធិរបស់ខ្ញុំតាមរបៀបណា?

ប្រសិនបើអ្នកមានសំណួរអំពីសិទ្ធិស្របច្បាប់របស់អ្នក ឬ ប្រសិនបើមជ្ឈមណ្ឌលក្នុងតំបន់មិនជួយដល់អ្នកឲ្យត្រៀមសម្រាប់វីរុស COVID-19 ទេនោះ៖

- សូមហៅទូរសព្ទទៅកាន់ខ្សែហៅចូលរបស់ DRC តាម៖ 1-800-776-5746.
- ហៅទៅកាន់ការិយាល័យការពារសិទ្ធិអតិថិជន (OCRA) តាមលេខ៖
    - Northern California 1-800-390-7032 (TTY 877-669-6023)
    - Southern California 1-866-833-6712 (TTY 877-669-6023).